ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម
រុក្ខាប្រមាញ់និងនេសាទ
លេខ ០២ ប្រក.កយ.កសក/០៤

# ប្រកាសរួម

## ស្ដីពីការដាក់ឲ្យប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបមាណីគុណភាព សម្ភារៈកសិកម្មដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

## ក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យបើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញក្រឹត្យលេខ ២១ ក្រ. ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី នីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣៦ មាត្រា៣៨ មាត្រា៩០ និង មាត្រា៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីការគ្រប់គ្រងឱសថ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នា២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្ដីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម

-បានឃើញប្រកាសលេខ ៣៥៦ ប្រក.កសក.បុ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០០២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីតិកម្មកសិកម្ម

-បានឃើញប្រកាសលេខ ២៧ ប្រក.រប.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌

-បានឃើញសារាចរណែនាំលេខ ៣៤៥ សរណន.កសក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០២ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨

-តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៤១៤៣ កសក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៣

**សម្រេច**

**ប្រការ ១** ត្រូវបានទទួលស្គាល់ដោយច្បាប់ជាមន្ត្រីនគរបាលយុត្តិធម៌ ឬ អាចបំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីរាជការនៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្មខេត្ត-ក្រុង រួមមាន ៖

-ប្រធាន និង អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម

-ប្រធាន និង អនុប្រធានមន្ទីរកសិកម្មខេត្ត-ក្រុង

-ប្រធាន និងអនុប្រធាន ការិយាល័យបមាណីសម្ភារៈកសិកម្ម ការិយាល័យនីតិកម្មកសិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម និង ការិយាល័យវិវាទកសិកម្ម និងស្រាវជ្រាវ

-ប្រធាន និង អនុប្រធានគ្រប់គ្រងការងារបមាណីសម្ភារៈកសិកម្មខេត្ត-ក្រុង ។

**ប្រការ ២** អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងប្រការ១ខាងលើប្រើប្រាស់ជាផ្លូវការនូវគំរូលិខិតដោះស្រាយបទល្មើសមានគុណភាពសម្ភារៈកសិកម្មរួមមាន ៖

១-កំណត់ហេតុចុះត្រួតពិនិត្យទីកន្លែងកើតហេតុ

២-កំណត់ហេតុនបទល្មើស

៣-កំណត់ហេតុបទល្មើសជាក់ស្តែង

៤-កំណត់ហេតុឆែកឆេរ

៥-កំណត់ហេតុសួរចម្លើយជនល្មើស

៦-កំណត់ហេតុសាកសួរបំភ្លឺ

៧-កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងជាបណ្តោះអាសន្ន

៨-កំណត់ហេតុយកគំរូសំណាកមកវិភាគ

៩-កំណត់ហេតុប្រគល់ និង ទទួលគ្រប់គ្រងវត្ថុតាង

១០-កំណត់ហេតុចាប់ឃាត់ខ្លួនជនល្មើស

១១-កំណត់ហេតុប្រគល់ និង ទទួលជនល្មើស

១២-សលាកប័ត្រទោសទណ្ឌ

១៣-ព្រឹត្តិបត្រព័ត៌មាន

១៤-របាយការណ៍សំយោគ

១៥-ដីកាអម ។

ដូចមានភ្ជាប់មកជាមួយនេះ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ងាយស្រួលបំពេញបែបបទប្រតិបត្តិការរបស់ខ្លួនឱ្យបានសមស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានបញ្ញត្តិ ។

**ប្រការ ៣** ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវស្ថិតនៅក្រោមការដឹកនាំសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានការស៊ើបអង្កេតដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធភាពដោយស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**ប្រការ ៤** មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដូចមានចែងក្នុងប្រការ១ខាងលើ អយ្យការអមតុលាការខេត្ត-ក្រុង និងគ្រប់តុលាការខេត្ត-ក្រុង ត្រូវអនុវត្តតាមគំរូសំណុំលិខិតដោះស្រាយបទល្មើសបមាណីគុណភាពសម្ភារៈកសិកម្មដូចមានចែងក្នុងប្រការ២ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥** ប្រកាសនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អង្គ វង្សវឌ្ឍានា** **ចាន់ សារុន**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

- សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ដូចប្រការ៤

-ឯកសារ -កាលប្បវត្តិ